ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

អ អ ក
EAC
**អាជ្ញាធរអគ្គិសនីកម្ពុជា**
លេខ៤២០.សណ១៧អអក

ភ្នំពេញ, ថ្ងៃទី ០៤ ខែ តុលា ឆ្នាំ២០១៧

# សេចក្តីណែនាំចំពោះអ្នកកាន់អាជ្ញាបណ្ណ
# ស្តីពីការយកថ្លៃសេវាផ្សេងៗ ក្នុងវិស័យអគ្គិសនីនៅកម្ពុជា ឲ្យបានត្រឹមត្រូវ

នាពេលកន្លងមក ទោះបីមានការណែនាំរបស់អាជ្ញាធរអគ្គិសនីកម្ពុជា ជាច្រើនលើកអំពីការអនុវត្តឲ្យបានត្រឹមត្រូវការយកថ្លៃសេវាផ្សេងៗក្នុងវិស័យអគ្គិសនីក៏ដោយ ក៏អាជ្ញាធរអគ្គិសនីកម្ពុជានៅសង្កេតឃើញថា មានអ្នកកាន់អាជ្ញាបណ្ណ និងបុគ្គលិករបស់អ្នកកាន់អាជ្ញាបណ្ណមួយចំនួន នៅប្រព្រឹត្តិអំពើខិលខូចយកថ្លៃសេវាផ្សេងៗ លើស ឬខុសពីគោលការណ៍កំណត់ ។ ពេលនេះ ដើម្បីបោសសំអាតបញ្ហាខុសឆ្គងនេះឲ្យអស់ក្នុងនាមជាស្ថាប័នត្រួតពិនិត្យការងារនេះ អាជ្ញាធរអគ្គិសនីកម្ពុជាសូមធ្វើការណែនាំ អ្នកផ្គត់ផ្គង់អគ្គិសនីទាំងអស់ ដូចខាងក្រោម ៖

១-ត្រូវបិទផ្សាយនូវសេចក្តីសម្រេចរបស់អាជ្ញាធរអគ្គិសនីកម្ពុជា លេខ ៤៦១.សរ.១៥.អអក ថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០១៥ ស្តីពីការកំណត់ថ្លៃភ្ជាប់ចរន្ត-ប្រាក់កក់ធានាថ្លៃប្រើប្រាស់អគ្គិសនី និងថ្លៃសេវាបម្រើអតិថិជន ដែលអ្នកផ្តល់សេវាអគ្គិសនីត្រូវអនុវត្តក្នុងការផ្គត់ផ្គង់អគ្គិសនី នៅក្នុងព្រះរាជាណាចក្រកម្ពុជា និងតារាងថ្លៃភ្ជាប់ចរន្ត-ប្រាក់កក់ និងថ្លៃសេវាផ្សេងៗ ជាសាធារណៈ ។ ទន្ទឹមនឹងនេះ ត្រូវអនុវត្តឲ្យបានត្រឹមត្រូវតាមគោលការណ៍កំណត់អំពីថ្លៃភ្ជាប់ចរន្ត-ប្រាក់កក់ និងថ្លៃសេវាបម្រើអតិថិជនផ្សេងៗ នោះ និងត្រូវត្រួតពិនិត្យណែនាំបុគ្គលិករបស់ខ្លួន ចៀសវាងការទារថ្លៃសេវាផ្សេងៗបន្ថែមខុសពីគោលការណ៍កំណត់ ។

២-ត្រូវចេញវិក្កយបត្រ និងបង្កាន់ដៃទទួលប្រាក់ គ្រប់ប្រភេទសេវាដែលខ្លួនមាន ជូនអតិថិជន ។

៣-មិនត្រូវបង្ខំឲ្យអតិថិជនទិញខ្សែភ្លើងសម្រាប់តចេញពីប្រអប់នាឡិកាស្ទង់ ទៅកាន់ទីតាំងរបស់អ្នកប្រើប្រាស់ ឬទិញខ្សែភ្លើង និងបរិក្ខាអគ្គិសនី សម្រាប់ប្រើប្រាស់នៅក្នុងទីតាំងរបស់អ្នកប្រើប្រាស់ ពីអ្នកផ្គត់ផ្គង់ ឬពីទីតាំងកំណត់ណាមួយឡើយ ។ ទន្ទឹមនឹងនេះ មិនត្រូវបង្ខំឲ្យអតិថិជនជួលបុគ្គលិករបស់ខ្លួន រៀបចំប្រព័ន្ធបណ្តាញអគ្គិសនីនៅក្នុងទីតាំងរបស់អ្នកប្រើប្រាស់ឡើយ ។ ក្នុងករណីអ្នកផ្គត់ផ្គង់មានបំណងចង់លក់ខ្សែភ្លើង និងបរិក្ខាអគ្គិសនី អ្នកផ្គត់ផ្គង់ត្រូវបង្ហាញបញ្ជីថ្លៃខ្សែភ្លើង-បរិក្ខាអគ្គិសនី និងថ្លៃសេវា ដែលខ្លួនចង់លក់នេះ ដើម្បីឲ្យអតិថិជនមានជម្រើសទិញ ឬមិនទិញ តាមបំណងរបស់គេផ្ទាល់ ។ ម្យ៉ាងវិញទៀត អ្នកផ្គត់ផ្គង់ត្រូវឲ្យបុគ្គលិករបស់ខ្លួនជួយអូសខ្សែភ្លើងសម្រាប់តចេញពីប្រអប់នាឡិកាស្ទង់ ទៅកាន់ទីតាំងរបស់អ្នកប្រើប្រាស់ ក្នុងករណីទីតាំងប្រើប្រាស់មានចម្ងាយក្រោម ១៥០ម៉ែត្រ ។

**អាជ្ញាធរអគ្គិសនីកម្ពុជា** : ផ្ទះលេខ ០២ ផ្លូវលេខ ២៨២ (ផ្លូវបត់ស្តាំទី ១ ខាងត្បូងវិមានឯករាជ្យ) សង្កាត់បឹងកេងកង ១ ខណ្ឌចំការមន រាជធានីភ្នំពេញ,
ទូរស័ព្ទ : ០២៣ ២១៧ ៦៥៤ / ៩៨៧ ៨៩៨ ទូរសារ : ០២៣ ២១៤ ១៤៤, អ៊ីម៉ែល : admin@eac.gov.kh ; Website : www.eac.gov.kh

៤-ក្នុងករណីអ្នកផ្គត់ផ្គង់ ឬបុគ្គលិករបស់អ្នកផ្គត់ផ្គង់ណាមួយ ទារប្រាក់លើស ឬខុសពីគោលការណ៍កំណត់ ហើយអ្នកអតិថិជនមិនព្រមបង់ ហើយអ្នកផ្គត់ផ្គង់ ឬបុគ្គលិករបស់អ្នកផ្គត់ផ្គង់នោះ កិកកុកមិនព្រមផ្តល់សេវាជូន ឬក៏ពន្យាពេល អាជ្ញាធរអគ្គិសនីកម្ពុជានឹងអន្តរាគមន៍ភ្លាម រួចកត់ត្រាទុកការប្រព្រឹត្តិខុសរបស់អ្នកផ្គត់ផ្គង់នោះ ដែលឈានដល់ការដាក់ពិន័យ ឬអនុវត្តតាមការកំណត់របស់ច្បាប់អគ្គិសនី ។

អាស្រ័យហេតុនេះ សូមអ្នកកាន់អាជ្ញាបណ្ណទាំងអស់ ជ្រាបជាព័ត៌មាន និងអនុវត្តសេចក្តីណែនាំនេះឲ្យមានប្រសិទ្ធភាព ។៚

**អាជ្ញាធរអគ្គិសនីកម្ពុជា**

**ប្រធាន**

**បណ្ឌិត.ធី នរិន្ទ**